ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រុមប្រឹក្សាធម្មនុញ្ញ

លេខ : ០៣៦/០៥/២០១៣ កបធ.សជណ

រាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែ កក្កដា ឆ្នាំ២០១៣

**ជម្រាបមក**

**កញ្ញា ទឹម ពុទ្ធា**

ទីលំនៅបច្ចុប្បន្ន ភូមិស្វាយគយ ឃុំពាន្លៃ ស្រុកបរិបូណ៌ ខេត្តកំពង់ឆ្នាំង

**កម្មវត្ថុ** : សុំប្តឹងបដិសេធសេចក្តីសម្រេចលេខ ០០២/១៣ គ.ជ.ប.ស.ស.រ ចុះថ្ងៃទី ១៦ ខែ កក្កដា ឆ្នាំ២០១៣ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។

**យោង** : - ច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ និង ច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់នេះ

- ច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និង ច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់នេះ
- បទបញ្ជា និង នីតិវិធីសម្រាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៥
- ពាក្យបណ្តឹងចុះថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ២០១៣ របស់កញ្ញា ទឹម ពុទ្ធា តំណាងគណបក្សប្រជាជនកម្ពុជា
- សេចក្តីសម្រេចលេខ ០០២/១៣ គ.ជ.ប.ស.ស.រ ចុះថ្ងៃទី ១៦ ខែ កក្កដា ឆ្នាំ២០១៣ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។

តបតាមកម្មវត្ថុ និង យោងខាងលើ ខ្ញុំសូមជម្រាបកញ្ញាថា ក្រុមប្រឹក្សាធម្មនុញ្ញបានទទួលពាក្យបណ្តឹងរបស់កញ្ញា និង បានដាក់ជូនក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យ ពិភាក្សាក្នុងកិច្ចប្រជុំពេញអង្គ នាថ្ងៃទី ២៥ ខែ កក្កដា ឆ្នាំ២០១៣ រួចហើយ ។ ក្រុមប្រឹក្សាធម្មនុញ្ញយល់ឃើញថា សេចក្តីសម្រេចលេខ ០០២/១៣ គ.ជ.ប.ស.ស.រ ចុះថ្ងៃទី ១៦ ខែ កក្កដា ឆ្នាំ២០១៣ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត មានលក្ខណៈត្រឹមត្រូវតាមច្បាប់ហើយ ។

សូមកញ្ញាទទួលនូវការរាប់អានអំពីខ្ញុំ ។

ជ.ក្រុមប្រឹក្សាធម្មនុញ្ញ
ប្រធាន

ឯក សិអុល

អាគារស វិមានរដ្ឋចំការមន មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន ភ្នំពេញ
ទូរស័ព្ទ/ ទូរសារ : (៨៥៥) ២៣ ៧២០ ៩១៣. E-mail: sgcc@camnet.com.kh/ info@ccc.gov.kh, Website :http://www.ccc.gov.kh